**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៤៦១សរ.-១៥ អអក

ភ្នំពេញ, ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០១៥

# សេចក្ដីសម្រេច

## ស្ដីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្ដល់សេវាអគ្គិសនីត្រូវអនុវត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងបទប្បញ្ញត្តិស្ដីពីលក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលអនុម័តដោយសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី១៤ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៣
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី២៨៧ថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០១៥

## សម្រេច

**ប្រការ ១ .-**

កំណត់ «ថ្លៃភ្ជាប់ចរន្ត» ដែលជាការចូលរួមចំណែកវិនិយោគរបស់អ្នកប្រើប្រាស់អគ្គិសនី លើហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ចរន្ត ស្របតាមការកំណត់នៃបទប្បញ្ញត្តិស្ដីពី «លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា» ដែលអ្នកស្នើសុំភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ធុនតូច ធុនមធ្យម ធុនធំ និងធុំ ត្រូវបង់នៅពេលស្នើសុំភ្ជាប់ចរន្តពីអ្នកផ្ដល់សេវាអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

១. ចំពោះអ្នកប្រើប្រាស់ធុនតូច

| កម្លាំងស្នើសុំប្រើប្រាស់ | ថ្លៃភ្ជាប់ចរន្ត | កាតព្វកិច្ចរបស់អ្នកផ្ដល់សេវាអគ្គិសនី |
|---|---|---|
| ក-ប្រភេទ ១ហ្វា | | |
| ៥ អាំពែរ | ៣១,០០០ រៀល | បន្ទាប់ពីអ្នកស្នើសុំបានបង់ថ្លៃភ្ជាប់រួច អ្នកផ្ដល់សេវាអគ្គិសនី ត្រូវទទួលបន្ទុកផ្ដល់សម្ភារៈឧបករណ៍ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធបន្តចរន្ត រហូតដល់ក្រោមចំណុចភ្ជាប់-ផ្ដាច់«ឌីស្យុងទ័រផ្គត់ផ្គង់» ដែលអ្នក |
| ១០ អាំពែរ | ៦២,០០០ រៀល | |
| ២០ អាំពែរ | ២២៨,០០០ រៀល | |
| ៣២ អាំពែរ | ៣៦៨,០០០ រៀល | |
| ៦៣ អាំពែរ | ៧៣៦,០០០ រៀល | |

| | | |
|---|---|---|
| ខ-ប្រភេទ ៣ហ្វា | | ស្នើសុំអាចភ្ជាប់ខ្សែរបស់ខ្លួន បន្តយកទៅប្រើប្រាស់បាន ។ សម្ភារៈ ឧបករណ៍ និងការតម្លើងខ្សែបណ្តាញចាប់ពីចំណុចភ្ជាប់-ផ្តាច់នេះ រហូតដល់ទីតាំងប្រើប្រាស់ គឺជាបន្ទុករបស់អ្នកស្នើសុំផ្ទាល់។ |
| ៣២ អាំពែរ | ១,១០៤,០០០ រៀល | |
| ៤០ អាំពែរ | ១,៣៦៨,០០០ រៀល | |
| ៦៣ អាំពែរ | ២,២០៨,០០០ រៀល | |
| ១០០ អាំពែរ | ៣,៣០០,០០០ រៀល | |

២. **ចំពោះអ្នកប្រើប្រាស់ធុនមធ្យម និងអ្នកប្រើប្រាស់ធុនធំ** ថ្លៃភ្ជាប់ចរន្ត ស្មើនឹងការទទួលបន្ទុកលើការតភ្ជាប់ពីចំណុចរបស់អ្នកផ្តល់សេវាអគ្គិសនី មកប្រព័ន្ធប្រើប្រាស់របស់អ្នកប្រើប្រាស់ រួមមានខ្សែបណ្តាញ ប្រព័ន្ធនាឡិកាស្ទង់ និងបរិក្ខាររួមផ្សំ ដែលអ្នកស្នើសុំ និងអ្នកផ្តល់សេវាអគ្គិសនីឯកភាពគ្នា។ ចំពោះការទទួលបន្ទុកខាងលើ អ្នកស្នើសុំអាចមានជម្រើស ២ គឺទី១.បង់ថ្លៃការតភ្ជាប់ឲ្យអ្នកផ្តល់សេវាអគ្គិសនី ដើម្បីអ្នកផ្តល់សេវាអគ្គិសនីរៀបចំជូន ឬទី២.អ្នកស្នើសុំទទួលបន្ទុករៀបចំការតភ្ជាប់ដោយខ្លួនឯង ឲ្យតែការតភ្ជាប់នេះ គោរពតាមស្តង់ដារបច្ចេកទេស សុវត្ថិភាព និងលទ្ធផលនៃការធ្វើតេស្តដំណើរការ អាចទទួលយកបានដោយអ្នកផ្តល់សេវាអគ្គិសនី។

៣. **ចំពោះអ្នកប្រើប្រាស់ដុំ** ការតភ្ជាប់ចរន្តមានលក្ខណៈពិសេសដែលប្រែប្រួល តាមករណីនីមួយៗ រួចការតភ្ជាប់ទៀតសោត នឹងអាស្រ័យលើការចូលរួមរវាងអ្នកផ្តល់សេវាបណ្តាញជាតិ និងអ្នកស្នើសុំ។ អាស្រ័យហេតុនេះ ថ្លៃភ្ជាប់ចរន្ត ចំពោះការតភ្ជាប់របស់អ្នកប្រើប្រាស់ដុំ នឹងកំណត់តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី រវាងអ្នកផ្តល់សេវាអគ្គិសនី ជាមួយអ្នកប្រើប្រាស់ ដែលអាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យផ្ទៀងផ្ទាត់ មុននឹងអនុញ្ញាតឲ្យចុះហត្ថលេខា។

៤. **និយមន័យរបស់អ្នកប្រើប្រាស់ធុនតូច ធុនមធ្យម ធុនធំ និងដុំ** មានចែងនៅក្នុងបទប្បញ្ញត្តិស្តីពី «លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា» ។

## ប្រការ ២ .-

កំណត់ការបង់ថ្លៃភ្ជាប់ចរន្តបន្ថែមសម្រាប់អ្នកប្រើប្រាស់អគ្គិសនីណា ដែលបានភ្ជាប់ចរន្តប្រើប្រាស់រួចហើយ ប៉ុន្តែមានបំណងតម្លើងកម្លាំងប្រើប្រាស់របស់ខ្លួន ដូចខាងក្រោម ៖

១. អ្នកប្រើប្រាស់ធុនតូច ត្រូវបង់ប្រាក់បន្ថែមបង្គ្រប់ថ្លៃនៃកម្លាំងដែលខ្លួនស្នើសុំថ្មី ពីលើថ្លៃដែលខ្លួនបានបង់មុន ។

២. អ្នកប្រើប្រាស់ធុនមធ្យម និងធុនធំ ទទួលបន្ទុកចេញថ្លៃកែសម្រួលនៃខ្សែបណ្តាញ ប្រព័ន្ធនាឡិកាស្ទង់ និងបរិក្ខាររួមផ្សំ ដើម្បីអាចប្រើប្រាស់តាមកម្លាំងស្នើសុំថ្មី។ សម្ភារៈ ឧបករណ៍ដែលនៅសល់មិនត្រូវប្រើនៅក្នុងការភ្ជាប់ចរន្តថ្មីនេះ ត្រូវឋិតនៅក្នុងសិទ្ធសម្រេចរបស់អ្នកស្នើសុំ ។

## ប្រការ ៣ .-

កំណត់ «ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី» ដែលជាប្រាក់តម្កល់ធានាថ្លៃប្រើប្រាស់អគ្គិសនីចំនួន ១ ខែមុន មុនពេលអ្នកផ្តល់សេវាអគ្គិសនី ចេញវិក្កយបត្រទារថ្លៃអគ្គិសនីដែលបានប្រើប្រាស់

រួច ។ អ្នកស្នើសុំប្រើប្រាស់អគ្គិសនីធុនតូច ធុនមធ្យម ធុនធំ និងដុំ ត្រូវបង់ នៅពេលស្នើសុំភ្ជាប់ចរន្ត ពីអ្នកផ្តល់សេវាអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

## ១. អ្នកប្រើប្រាស់ធុនតូច

| កម្លាំងស្នើសុំ ប្រើប្រាស់ | មាត្រដ្ឋានគិតប្រាក់កក់ ធានាថ្លៃប្រើប្រាស់អគ្គិសនី | | |
|---|---|---|---|
| | អតិថិជនលំនៅដ្ឋាន និងអាគាររដ្ឋបាល | អតិថិជនអាជីវកម្ម និងសិប្បកម្ម | អតិថិជនផ្ទះជួលបរទេស សណ្ឋាគារ និងស្ថានទូត |
| ក- ប្រភេទ ១ ហ្វា | | | |
| ៥ អំពែរ | ៥អំពែរ x ៧.៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៥អំពែរ x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៥អំពែរ x ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ១០ អំពែរ | ១០អំពែរ x ៧.៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១០អំពែរ x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១០អំពែរ x ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ២០ អំពែរ | ២០អំពែរ x ៧.៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ២០អំពែរ x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ២០អំពែរ x ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ៣២ អំពែរ | ៣២អំពែរ x ១៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អំពែរ x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អំពែរ x ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ៦៣ អំពែរ | ៦៣អំពែរ x ១៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អំពែរ x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អំពែរ x ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ខ- ប្រភេទ ៣ ហ្វា | | | |
| ២០ អំពែរ | ២០អំពែរ x ៣ហ្វា x ១៥ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ២០អំពែរ x ៣ហ្វា x ៣០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ២០អំពែរ x ៣ហ្វា x ៤០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ៣២ អំពែរ | ៣២អំពែរ x ៣ហ្វា x ១៥ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អំពែរ x ៣ហ្វា x ៣០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អំពែរ x ៣ហ្វា x ៤០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ៤០ អំពែរ | ៤០អំពែរ x ៣ហ្វា x ១៥ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៤០អំពែរ x ៣ហ្វា x ៣០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៤០អំពែរ x ៣ហ្វា x ៤០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ៦៣ អំពែរ | ៦៣អំពែរ x ៣ហ្វា x ១៥ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អំពែរ x ៣ហ្វា x ៣០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អំពែរ x ៣ហ្វា x ៤០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ៩០ អំពែរ | ៩០អំពែរ x ៣ហ្វា x ១៥ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៩០អំពែរ x ៣ហ្វា x ៣០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៩០អំពែរ x ៣ហ្វា x ៤០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ១០០ អំពែរ | ១០០អំពែរ x ៣ហ្វា x ១៥ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១០០អំពែរ x ៣ហ្វា x ៣០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១០០អំពែរ x ៣ហ្វា x ៤០ គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |

## ២.អ្នកប្រើប្រាស់ធុនមធ្យម

ចំពោះការស្នើសុំភ្ជាប់ចរន្ត ដែលមានអានុភាពចាប់ពី ៥០ kVA ដល់ ២៧៥ kVA (កាវ៉េអា) ប្រាក់កក់ធានាអប្បបរមា ដែលអ្នកស្នើសុំមានកាតព្វកិច្ចត្រូវតម្កល់ទុក ដើម្បីធានាលើបរិមាណថាមពលអគ្គិសនីបានប្រើប្រាស់មុន ១ ខែ មុនពេលចេញវិក្កយបត្រ ត្រូវគណនាតាមរូបមន្ត ខាងក្រោម ៖

= ទំហំស្នើសុំជា កាវ៉េអា x ៧០% x 0.៩ x ១០ ម៉ោង x ២៥ ថ្ងៃ x ៥០% x អត្រាថ្លៃលក់ ។

៣.អ្នកប្រើប្រាស់ធុនធំ

ចំពោះការស្នើសុំភ្ជាប់ចរន្ត ដែលមានអានុភាពចាប់ពី ២៧៥ kVA (ការ៉េអា) ដល់ ១០ MVA (មេហ្គាវ៉ុលអំពែរ) ប្រាក់កក់ធានាអប្បបរមា ដែលអ្នកស្នើសុំមានកាតព្វកិច្ចត្រូវតម្កល់ទុកនៅពេលស្នើសុំដំបូង ដើម្បីធានាលើបរិមាណថាមពលអគ្គិសនីដែលបានប្រើប្រាស់មុន ១ ខែ មុនពេលចេញវិក្កយបត្រ ត្រូវគណនាតាមអានុភាពតម្លើង និងតាមរូបមន្ត ដូចខាងក្រោម ៖

- ចំពោះអានុភាពស្នើសុំ ចាប់ពី ២៧៥ ការ៉េអា ដល់ ១,០០០ ការ៉េអា

  = ទំហំស្នើសុំជា ការ៉េអា x ៦០% x ០.៩ x ១០ ម៉ោង x ២៥ ថ្ងៃ x ៥០% x អត្រាថ្លៃលក់

- ចំពោះអានុភាពស្នើសុំចាប់ពី ១,០០១ ការ៉េអា ដល់ ៣,០០០ ការ៉េអា

  = ទំហំស្នើសុំជា ការ៉េអា x ៦០% x ០.៩ x ១០ ម៉ោង x ២៥ ថ្ងៃ x ៤០% x អត្រាថ្លៃលក់

- ចំពោះអានុភាពស្នើសុំចាប់ពី ៣,០០១ ការ៉េអា ដល់ ១០ មេហ្គាវ៉ុលអំពែរ

  = ទំហំស្នើសុំជា ការ៉េអា x ៦០% x ០.៩ x ១០ ម៉ោង x ២៥ ថ្ងៃ x ៣០% x អត្រាថ្លៃលក់

៤.អ្នកប្រើប្រាស់ធំ

ចំពោះការស្នើសុំភ្ជាប់ចរន្ត ដែលមានអានុភាពចាប់ពី ១០ MVA (មេហ្គាវ៉ុលអំពែរ) ឡើងទៅ ប្រាក់កក់ធានាអប្បបរមា ដែលអ្នកស្នើសុំមានកាតព្វកិច្ចត្រូវតម្កល់ទុកនៅពេលស្នើសុំដំបូង ដើម្បីធានាលើបរិមាណថាមពលអគ្គិសនីដែលបានប្រើប្រាស់មុន ១ ខែ មុនពេលចេញវិក្កយបត្រ ត្រូវគណនាតាមរូបមន្ត = ទំហំស្នើសុំជា ការ៉េអា x ៦០% x ០.៩ x ១០ ម៉ោង x ២៥ ថ្ងៃ x ៣០% x អត្រាថ្លៃលក់។

«ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី» នេះ អនុវត្តតែសម្រាប់ស្នើសុំភ្ជាប់ចរន្តថ្មីប៉ុណ្ណោះ។ ក្នុងករណីក្រោយពេលភ្ជាប់ចរន្តរួច ប្រសិនបើកំណើនការប្រើប្រាស់របស់អតិថិជនកើនឡើង លើសពីបរិមាណថាមពលអប្បបរិមាខាងលើចំនួន ៣ ខែជាប់គ្នា អ្នកផ្គត់ផ្គង់អគ្គិសនី អាចតម្រូវឲ្យអ្នកប្រើប្រាស់បង់ប្រាក់កក់បន្ថែម ឲ្យស្មើនឹងចំនួនដែលកើនឡើងនោះ។

**ប្រការ ៤ .-**

ក្នុងករណីអ្នកស្នើសុំភ្ជាប់ចរន្ត ជាអ្នកចេញថ្លៃវិនិយោគលើខ្សែបណ្តាញ សម្ភារៈឧបករណ៍ត្រង់ស្វូ បន្ទាប់ពីភ្ជាប់ចរន្តរួច ឧបករណ៍ និងសម្ភារៈទាំងនេះ ឋិតនៅជាកម្មសិទ្ធរបស់អ្នកស្នើសុំប្រើប្រាស់ ។ អ្នកប្រើប្រាស់នោះ អាចចរចាជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីតម្កល់ទុកខ្សែបណ្តាញ សម្ភារៈឧបករណ៍ ត្រង់ស្វូទាំងនោះ ជាការធានាចំពោះផ្នែកណាមួយ ឬទាំងអស់នៃប្រាក់កក់ អាស្រ័យទៅ តាមការឯកភាពរបស់ភាគីទាំង ២។ ការឯកភាពនេះ ត្រូវមានចែងក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី ។

**ប្រការ ៥ .-**

ពេលអ្នកស្នើសុំបង់ប្រាក់កក់រួច អ្នកផ្គត់ផ្គង់សេវាអគ្គិសនី ត្រូវចេញប័ណ្ណប្រាក់កក់ឲ្យអ្នកស្នើសុំ

ដើម្បីជាកស្តុតាង និងសម្រាប់ដក «ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី» នេះវិញ នៅពេលបញ្ចប់កិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី។ អ្នកផ្តល់សេវាអគ្គិសនីត្រូវប្រគល់ប្រាក់កក់ធានានេះ ឲ្យទៅអ្នកប្រើប្រាស់វិញ ក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ បន្ទាប់ពីកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនីត្រូវបានបញ្ចប់ និងបន្ទាប់ពីអ្នកប្រើប្រាស់បានទូទាត់បំណុលរួច ។

**ប្រការ ៦** .-

អតិថិជនកំពុងប្រើប្រាស់អគ្គិសនី ដែលបានភ្ជាប់ចរន្តប្រើប្រាស់ហើយ ហើយកំពុងតែបន្តការប្រើប្រាស់ធម្មតា ពុំមានកាតព្វកិច្ចត្រូវបង់ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី ដែលកំណត់ក្នុងប្រការ ៣ ខាងលើឡើយ ដោយចាត់ទុកដូចជាបានបង់ប្រាក់កក់ តាមកម្លាំងប្រើប្រាស់រួចហើយ ទោះជារូបភាពនៃការបង់ប្រាក់កក់ពីមុន មានលក្ខណៈខុសពីការកំណត់ក្នុងប្រការ ៣ ខាងលើក៏ដោយ ។ ក្នុងករណីដែលអ្នកប្រើប្រាស់ ធុនតូច ធុនមធ្យម ធុនធំ និងដុំ កំពុងប្រើប្រាស់អគ្គិសនីហើយមានបំណងតម្លើងកម្លាំងប្រើប្រាស់របស់ខ្លួនបន្ថែម អ្នកប្រើប្រាស់នោះ ត្រូវបង់ប្រាក់កក់ធានាការប្រើប្រាស់អគ្គិសនីបន្ថែមបង្គ្រប់ តាមអត្រាកំណត់ថ្មីក្នុងប្រការ ៣ តាមរូបមន្តប្រាក់កក់បង្គ្រប់ស្មើចំនួនប្រាក់កក់ តាមអានុភាពស្នើសុំថ្មី ដកចំនួនប្រាក់កក់ពីមុនដែលមានស្រាប់ ។

**ប្រការ ៧** .-

ចំពោះ «ថ្លៃភ្ជាប់ចរន្ត» និង «ប្រាក់កក់ធានាថ្លៃប្រើប្រាស់» អ្នកផ្តល់សេវាអគ្គិសនីអាចពិនិត្យលទ្ធភាពផ្តល់ការអនុគ្រោះដល់អតិថិជនអ្នកស្នើសុំភ្ជាប់ចរន្តថ្មី ឲ្យគេអាចពន្យាពេលបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី ឬអាចបង់រំលស់ច្រើនលើកបាន ។ រយៈពេលអនុគ្រោះ និងចំនួនលើកត្រូវបង់ ត្រូវកំណត់ដោយយោងទៅតាមទំនុកចិត្តរបស់អ្នកផ្តល់សេវាអគ្គិសនី លើអ្នកស្នើសុំភ្ជាប់ចរន្ត។

**ប្រការ ៨** .-

អ្នកផ្តល់សេវាអគ្គិសនីមានសិទ្ធធ្វើការពិសោធន៍ ដើម្បីត្រួតពិនិត្យធ្វើការផ្លាស់ប្តូរ និងធ្វើឲ្យទាន់សម័យប្រព័ន្ធនាឡិកាស្ទង់របស់អ្នកប្រើប្រាស់ ដែលកំពុងភ្ជាប់ជាមួយបណ្តាញចែកចាយរបស់ខ្លួនបាន ប៉ុន្តែរាល់ការចំណាយសម្រាប់អ្នកប្រើប្រាស់ធុនតូច គឺជាបន្ទុករបស់អ្នកផ្តល់សេវាអគ្គិសនីលើកលែងតែករណីអ្នកប្រើប្រាស់ប្រព្រឹត្តិល្មើស ដោយធ្វើឲ្យប្រព័ន្ធនាឡិកាស្ទង់ដំណើរការមិនប្រក្រតី ឬខូចលែងដំណើរការ។សម្រាប់អ្នកប្រើប្រាស់ធុនមធ្យម ធុនធំ និងដុំ គឺជាបន្ទុករបស់អ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិស្តីពី «លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា»។

**ប្រការ ៩** .-

អនុញ្ញាតឲ្យអ្នកផ្តល់សេវាអគ្គិសនី យកថ្លៃសេវាបម្រើអតិថិជន ស្របតាមការកំណត់នៃបទប្បញ្ញត្តិស្តីពី «លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា» ទៅតាមថ្លៃ

សេវា ដូចមានកំណត់ខាងក្រោម ៖

| បរិយាយ | ថ្លៃសេវាបម្រើអតិថិជន |
|---|---|
| ១.ថ្លៃសេវាប្រើប្រាស់អគ្គិសនីអប្បបរមាប្រចាំខែ | |
| គ្រប់ទំហំអំពែរ និងគ្រប់ប្រភេទអតិថិជន | ១,៥០០ រៀល ក្នុង ១ ខែ |
| ២.ថ្លៃសេវាផ្តាច់-ភ្ជាប់ការផ្គត់ផ្គង់ចរន្តអគ្គិសនី លើទីតាំងប្រើប្រាស់អគ្គិសនីដែលជាប់ជំពាក់ថ្លៃប្រើប្រាស់អតិថិជនហួសកាលកំណត់ នៅក្នុងវិក្កយបត្រប្រើប្រាស់ប្រចាំខែ | |
| អតិថិជនតង់ស្យុងទាប | ១០,០០០ រៀល ក្នុង ១ ដង |
| អតិថិជនតង់ស្យុងមធ្យម | ២០,០០០ រៀល ក្នុង ១ ដង |
| ៣.ថ្លៃសេវាសុំផ្អាកការប្រើប្រាស់អគ្គិសនីបណ្តោះអាសន្ន | |
| គ្រប់ទំហំអំពែរ និងគ្រប់ប្រភេទអតិថិជន | ៤០,០០០ រៀល ក្នុង ១ ដង |
| ៤.ថ្លៃសេវាពិនិត្យផ្ទៀងផ្ទាត់លេខអំណាននាឡិកាស្ទង់ (ករណីពិនិត្យឃើញថា ស្រង់លេខអំណាននាឡិកាស្ទង់ត្រឹមត្រូវ អ្នកប្រើប្រាស់ត្រូវបង់ថ្លៃសេវាផ្ទៀងផ្ទាត់ ។ ករណីពិនិត្យឃើញថា ស្រង់លេខអំណាននាឡិកាស្ទង់ខុស អ្នកប្រើប្រាស់ ពុំតម្រូវឲ្យបង់ថ្លៃសេវាទេ។ | |
| ប្រភេទលំនៅដ្ឋានធម្មតា | ៥,០០០ រៀល ក្នុង ១ ដង |
| ប្រភេទក្រៅពីលំនៅដ្ឋានធម្មតា | ១០,០០០ រៀល ក្នុង ១ ដង |

**ប្រការ ១០ .-**

សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិស្តីពី «លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា» ។ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១ .-**

អ្នកផ្តល់សេវាអគ្គិសនី មានភារៈកិច្ចផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះជាមួយអ្នកប្រើប្រាស់របស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធនិងទទួលបន្ទុកអនុវត្តឲ្យមានប្រសិទ្ធភាព។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

<u>ចម្លងជូន</u> ៖

- ក្រសួងរ៉ែ និងថាមពល
- សាលារាជធានីភ្នំពេញ-សាលាខេត្ត ពាក់ព័ន្ធ
- មន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត ពាក់ព័ន្ធ
- សាលាក្រុង-ខណ្ឌ-ស្រុក ពាក់ព័ន្ធ
- សាលាឃុំ-សង្កាត់ ពាក់ព័ន្ធ
  «ដើម្បីជូនជ្រាប»
- អ្នកផ្តល់សេវាអគ្គិសនី ពាក់ព័ន្ធ
  «ដើម្បីផ្សព្វផ្សាយ និងអនុវត្ត»
- ឯកសារ-កាលប្បវត្តិ